# Car Seats អាចជួយស្រង់ជីវិតក្មេងបាន

Car Seats Save Young Lives
WUML
1/25/09

ការសិក្សាពេលថ្មីៗនេះ បញ្ជាក់ឲ្យដឹងថា ការដាក់កូនឲ្យអង្គុយក្នុង Car Seat ត្រឹមត្រូវទៅតាមអាយុដែលត្រូវប្រើ អាចជួយការពារកុំឲ្យកូន មានគ្រោះថ្នាក់ស្លាប់បាត់បង់ជីវិត បានយ៉ាងច្រើន។

ចំនួនគ្រោះថ្នាក់ទាំងនេះ អាចចុះបាន 3/4 នៃគ្រោះថ្នាក់រថយន្តទាំងអស់ ប្រសិនបើឲ្យកូនជិៈក្នុង Car Seat។ Car Seat ក៏អាចជួយកាត់បន្ថយកុំឲ្យក្មេងធំៗ មានគ្រោះថ្នាក់បាន យ៉ាងហោចណាស់ ចំនួន 60% ផងដែរ។

លទ្ធផលនៃការសិក្សានេះបាន ចុះផ្សាយក្នុងសារពត៌មានអាមេរិកាំង ផ្នែកសាធារណៈសុខាភិបាល, American Journal of Public Health, ក្នុងខែ កុម្ភៈខាងមុខនេះ។

យោលទៅតាម ការសិក្សានេះ គ្រោះថ្នាក់រថយន្ត ជាគ្រោះថ្នាក់មួយដែល បណ្តាលឲ្យក្មេងអាយុពីមួយឆ្នាំឡើងទៅ មានរបួសឬស្លាប់បាត់បង់ជីវិត។ ហើយ យោលទៅតាម មជ្ឈមណ្ឌលបង្ក្រាបនិងការពារជម្ងឺនៃសហរដ្ឋ, U.S. Center for Disease Control and Prevention នៅក្នុងឆ្នាំ 2005 មានក្មេងអាយុ ក្រោម 3 ឆ្នាំ ចំនួន 500 នាក់ ដែលបានស្លាប់ ដោយសារគ្រោះថ្នាក់រថយន្ត។

ទីស្នាក់ការ រដ្ឋាភិបាលទទួលបន្ទុកខាងសន្តិសុខតាមផ្លូវជាតិ, National Highway Safety Administration, បានប៉ាន់ស្មានថា នៅក្នុងឆ្នាំ 2006 មានក្មេងក្រោមអាយុ មួយឆ្នាំ ចំនួន 93% និងក្មេងអាយុចន្លោះ ពី 1 ឆ្នាំ ទៅ 3 ឆ្នាំ ចំនួន 91% ប្រើ Car Seat នៅពេលជិៈរថយន្ត។

ក្នុងការសិក្សានេះ អ្នកស្រាវជ្រាវ បានសិក្សា អំពីចំនួន ក្មេងទាំងអស់ ដែលស្លាប់ដោយសារគ្រោះថ្នាក់រថយន្ត ក្នុងចន្លោះពេលពីឆ្នាំ 1996 ទៅឆ្នាំ 2005។

ទារកអាយុក្រោមមួយឆ្នាំ ដែលស្លាប់ដោយសារគ្រោះថ្នាក់រថយន្តបានចុះចំនួន 73% ប្រសិនបើទារកនោះ អង្គុយក្នុង Car Seat ។ ចំពោះក្មេងអាយុពី 1 ឆ្នាំ ទៅ 2 ឆ្នាំវិញ ចំនួននេះ អាចចុះដល់ 76%។ ឯក្មេងអាយុពី 2 ឆ្នាំ ទៅទល់និង 3 ឆ្នាំ ការស្លាប់ដោយសារគ្រោះថ្នាក់រថយន្ត អាចចុះរហូតដល់ 60%។ នេះគឺបានន័យថា ប្រសិនបើក្មេងទាំងនោះអង្គុយក្នុង Car Seat ។

គេបានដឹងថា Car Seat អាចជួយការពារនិងជួយសង្គ្រោះជីវិតក្មេងបាន នៅពេលណា ដែលមានរថយន្ត ក្រឡាប់, ឬរថយន្ត truck ភ្លូក នៅតាមតំបន់ជនបត់ ដាច់ស្រយ៉ាលពីទីក្រុង។

ចំពោះក្មេងធំៗ ដែលមានអាយុពី 2 ឆ្នាំ ទៅទល់និង 3ឆ្នាំ ខ្សែក្រវ៉ាត់ ក៏អាចជួយការពារ កុំឲ្យក្មេងទសងនោះ មានរបួស ឬស្លាប់បាត់បង់ជីវិត ដូច Car Seat អញ្ចឹងដែរ។ ប៉ុន្តែ អ្នកឯកទេសខាងការពារគ្រោះថ្នាក់សំរាប់ក្មេង ផ្តល់យោបល់ថា ការឲ្យក្មេងអាយុ ពី 2ឆ្នាំ ទៅ 3ឆ្នាំ ពាក់ខ្សែប្រវ៉ាត់នេះ ពុំមែន ជាការមួយល្អដែរ។

វេជ្ជបណ្ឌិត Barbara Gaines នាយិកាផ្នែកកម្មវិធីព្យាបាលក្មេងរបួសដោយសារគ្រោះថ្នាក់ផ្សេងៗ នៅ Benedum នៃមន្ទីរពេទ្យកុមារនៅទីក្រុង Pittsburg រដ្ឋ Pen, Benedum Pediatric Trauma Program at Children Hospital in Pittburg, Penn, មានប្រសាសន៍ថា អ្វីក៏ដោយ ដែលអាចជួយទប់ក្រៀកក្មេងក្នុងរថយន្ត អាចជួយកាត់បន្ថយគ្រោះថ្នាក់ស្លាប់បាន។ ដូច្នេះ ចំពោះក្មេងធំៗ ខ្សែក្រវ៉ាត់ ក៏អាចជួយទប់ក្រៀកក្មេងនោះបានដែរ។ ប៉ុន្តែ ខ្សែក្រវ៉ាត់ ពុំអាចជួយសង្គ្រោះក្មេង នៅពេលណា ដែលមានគ្រោះថ្នាក់រថយន្តខ្លាំងនោះឡើយ។

អ្នកស្រីវេជ្ជបណ្ឌិត បន្ថែមទៀតថា ការសិក្សានេះ បញ្ជាក់ឲ្យដឹងថា ការប្រើ Car Seat សំរាប់ក្មេង ឲ្យបានត្រឹមត្រូវ ទៅតាមអាយុ ជាកត្តាមួយ យ៉ាងសំខាន់បំផុត ដើម្បីការពារ ជៀសវាងកុំឲ្យក្មេង មានគ្រោះថ្នាក់របួសឬ មានគ្រោះថ្នាក់ រហូតដល់ស្លាប់បាត់បង់ជីវិតបាន។ អ្នកស្រីផ្តល់យោបល់ថា៖

- ក្មេងដែលមានអាយុតិចជាងមួយឆ្នាំ គួរប្រើ Car Seat ដែលបែរមុខ ទៅក្រោយរថយន្ត
- Car Seat ធម្មតា ឬ Convertible Seat គឺសំរាប់ក្មេងដែលមានអាយុពី 1 ឆ្នាំទៅ 3 ឆ្នាំ
- Booster Seat, គឺសំរាប់ក្មេងដែលមានអាយុពី 4 ឆ្នាំ ទៅទល់នឹង 8 ឆ្នាំ

ម្យ៉ាងទៀត គួរពិនិត្យមើល ទម្ងន់របស់ក្មេង ដែលត្រូវអង្គុយ ឲ្យសមស្របទៅតាម Car Seat នោះផងដែរ។ ទោះបី ជាក្មេងធំ អាយុច្រើន ឈប់ប្រើ Booster Seat ក៏ដោយ ក៏ក្មេងនោះត្រូវការប្រើខ្សែក្រវ៉ាត់ដែរ ជាពិសេស ចំពោះក្មេងជំទង់ Teenagers។

ចំពោះពត៍មានបន្ថែម ស្តីអំពីការប្រើ Car Seat កុំឲ្យមានគ្រោះថ្នាក់ សូមមេត្តាអានវិបសៃរបស់បណ្ឌិតសភាអាមេរិកាំងផ្នែកពេទ្យកុមារ, American Academy of Pediatrics ដែលមានអាសយដ្ឋាន www.aap.org/family/carseatguide ។

Source:http://healthfinder.gov/news/newsstory.aspx?docID=623150